Employment Security Department
WASHINGTON STATE

# ការបដិសេធផ្ដល់ជូនការងារ

អ្នកអាចនឹងត្រូវបានបដិសេធមិនផ្ដល់ជូនអត្ថប្រយោជន៍សម្រាប់ភាពអត់ការងារធ្វើ ប្រសិនបើអ្នកបដិសេធការផ្ដល់ជូនការងារដែលស័ក្តិសម។ អ្នកត្រូវបានតម្រូវឲ្យរាយការណ៍អំពីការផ្ដល់ជូនការងារណាមួយដែលអ្នកបានបដិសេធពេលដាក់ពាក្យទាមទារសុំអត្ថប្រយោជន៍ និងមានមូលហេតុជាបុព្វហេតុល្អក្នុងការមិនព្រមទទួលយកការងារដែលស័ក្តិសម។

- **ការងារស័ក្តិសម** គឺស្របគ្នាជាមួយនឹងការបណ្ដុះបណ្ដាល បទពិសោធន៍ការងារ ការអប់រំពីមុន សុខភាព សុវត្ថិភាព និងសីលធម៌របស់អ្នក។
- **បុព្វហេតុល្អ** ត្រូវបានបង្កើតឡើងនៅពេលអ្នកមានហេតុផលផ្ទាល់ខ្លួន និងខាងមិនបានសម្រាប់បដិសេធការផ្ដល់ជូនការងារ។
- **ការទាមទារអត្ថប្រយោជន៍ដែលបោកបន្លំ** កើតមានឡើងនៅពេលអ្នកផ្ទិបទុកព័ត៌មានដោយចេតនា រួមមានការបដិសេធការងារ នៅពេលទាមទារសុំអត្ថប្រយោជន៍។

# បុគ្គលដែលរាយការណ៍ពីការផ្ដល់ជូនការងារ

អ្នកត្រូវតែរាយការណ៍ពេលអ្នកច្រានចោលការផ្ដល់ជូនការងារ ដោយសារមូលហេតុណាមួយនៅលើពាក្យទាមទារសុំអត្ថប្រយោជន៍សម្រាប់ភាពអត់ការងារធ្វើប្រចាំសប្ដាហ៍របស់អ្នក។ យ៉ាងណាក៏ដោយ ប្រសិនបើអ្នកមានមូលហេតុជា "បុព្វហេតុល្អ" សម្រាប់ការច្រានការងារ នោះអត្ថប្រយោជន៍អាចនឹងនៅតែមានដដែល។

យើងនឹងផ្ញើជូនអ្នកនូវកម្រងសំណួរតាមរយៈប្រៃសណីយ៍ ឬ eServices។ ឧទាហរណ៍នៃសំណួរខ្លះៗនៃសំណួរទាំងអស់គឺ៖

- តើអ្វីជាមូលហេតុសម្រាប់ការបដិសេធការផ្ដល់ជូនការងារ?

- តើការផ្តល់ជូនការងារត្រូវបានធ្វើឡើងនៅថ្ងៃណា?
- តើការផ្តល់ជូនការងារត្រូវបានធ្វើឡើងតាមវិធីសាស្ត្រអ្វី? (តាមទូរសព្ទ អ៊ីមែល ឬក៏សំបុត្រ)
- តើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រភេទការងារដែលបានផ្តល់ជូនដែរទេ?

ប្រសិនបើអ្នកកំពុងទទួលអត្ថប្រយោជន៍នៅពេលដែលអ្នកបដិសេធការផ្តល់ជូនការងារ យើងនឹងបន្តបង់អត្ថប្រយោជន៍ប្រចាំសប្តាហ៍ដោយមានលក្ខខណ្ឌស្របពេលដែលកំណត់ភាពមានសិទ្ធិបន្តរបស់អ្នកសម្រាប់អត្ថប្រយោជន៍ក្នុងពេលអត់ការងារធ្វើ។ យើងនឹងប្រមូលយកអត្ថប្រយោជន៍ដែលមិនមានសិទ្ធិទទួលវិញ ប្រសិនបើនៅពេលក្រោយមកទៀតយើងកំណត់ថាអ្នកមិនមានសិទ្ធិទទួលបាន។

# ការងារដែលស័ក្តសម

យើងចាត់ទុកការងារថា "ស័ក្តសម" នៅពេលដែលវាស្របជាមួយនឹងការបណ្តុះបណ្តាល បទពិសោធន៍ការងារ និងការអប់រំពីមុនរបស់អ្នក។ ពេលត្រូវបានផ្តល់ជូនការងារ អ្នកគួរតែសួរខ្លួនឯង៖

- តើខ្ញុំមានបទពិសោធន៍ដើម្បីធ្វើការងារនោះដែរឬទេ?
- ក្រៅពីការបណ្តុះបណ្តាលនៅក្នុងពេលបំពេញការងារ តើខ្ញុំត្រូវតែមានការបណ្តុះបណ្តាល ឬការអប់រំថែមទៀត ដើម្បីអាចធ្វើការងារនោះដែរឬទេ?
- តើខ្ញុំបានធ្វើការងារប្រភេទនេះពីមុនមកទេ?

យើងក៏នឹងពិចារណាទៅលើកម្រិតហានិភ័យដែលពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព និងសីលធម៌របស់អ្នកផងដែរនៅក្នុងការកំណត់ថាតើការងារនោះស័ក្តសមដែរឬទេ។ ក្នុងអំឡុងភាពអាសន្នផ្នែកសុខភាពសាធារណៈ: យើងក៏នឹងពិចារណាលើកម្រិតហានិភ័យដែលការផ្តល់ជូនការងារនឹងមានទៅលើសុខភាពរបស់អ្នកដែលស្នាក់នៅជាមួយអ្នកផងដែរ។

# បុព្វហេតុល្អ

ការងារមិនត្រូវបានចាត់ទុកថាស័ក្តិសមទេ នៅពេលដែលមានមូលហេតុជា "បុព្វហេតុល្អ" សម្រាប់ការបដិសេធការផ្តល់ជូនការងារ។ "បុព្វហេតុល្អ" អាចត្រូវបានបង្កើតឡើង ប្រសិនបើវាត្រូវបានបង្ហាញថា អ្នកមានហេតុផលផ្ទាល់ខ្លួន និងដែលចាំបាច់សម្រាប់ការបដិសេធការផ្តល់ជូនការងារ។

ឧទាហរណ៍៖

- អ្នកមានអាយុ 65 ឆ្នាំឡើងទៅ ឬត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់ដោយ Centers for Disease Control and Prevention (ជាភាសាអង់គ្លេស) ក្នុងអំឡុងភាពអាសន្នផ្នែកសុខភាពសាធារណៈ។
- អ្នកកំពុងរស់នៅជាមួយនរណាម្នាក់ដែលត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់។
- ទីកន្លែងធ្វើការមិនមានសុវត្ថិភាព។

ក្នុងខណៈដែលអ្នកអាចមានបុព្វហេតុល្អ ដើម្បីបដិសេធការងារដែលស័ក្តិសម មូលហេតុខ្លះនឹងបណ្តាលឲ្យយើងសួរអ្នកនូវភាពទំនេរសម្រាប់ធ្វើការរបស់អ្នក។

អ្នកមិនអាចប្រានចោលការងារ ហើយរក្សាទុកអត្ថប្រយោជន៍បានឡើយដោយសារមូលហេតុដូចជា៖

- អ្នករកប្រាក់បានច្រើននៅក្នុងភាពអត់ការងារធ្វើជាងអ្នករកបាននៅក្នុងការងារដែលបានផ្តល់ជូន។
- អ្នកមិនចង់ធ្វើការ។
- អ្នកមានអារម្មណ៍ភ័យព្រួយអំពីការវិលត្រលប់ទៅធ្វើការវិញ ប៉ុន្តែមិនមានមូលហេតុដែលត្រូវបានព្រមទទួលយកមួយផ្សេងទៀតទេដើម្បីបដិសេធ។
- អ្នកមិនចូលចិត្តការងារដែលត្រូវបានផ្តល់ជូន បើទោះបីជាវាជាការងារស័ក្តិសមក៏ដោយ។
- អ្នកចង់ផ្លាស់ប្តូរអាជីព។
- អ្នកកំពុងរៀននៅក្នុងសាលារៀន។

- អ្នកនឹងវិលត្រលប់ទៅធ្វើការងារធម្មតារបស់អ្នកវិញ ប៉ុន្តែមិនដឹងថាពេលណា។
- អ្នកកំពុងរង់ចាំនិយោជកផ្សេងពីនេះផ្ដល់ជូនអ្នកនូវការងារ។

# ទីកន្លែងការងារគ្មានសុវត្ថិភាព

និយោជករបស់រដ្ឋវ៉ាស៊ីនតោនត្រូវអនុវត្តតាមលក្ខខណ្ឌ និងការណែនាំរបស់ Centers for Disease Control and Prevention(CDC) និង Department of Labor and Industries របស់រដ្ឋ និង Washington State Department of Health ដើម្បីរក្សាទីកន្លែងធ្វើការប្រកបដោយសុវត្ថិភាព (តំណភ្ជាប់ជាភាសាអង់គ្លេស)។

ប្រសិនបើអ្នកបដិសេធចំពោះការផ្តល់ជូនការងារដោយសារតែកង្វល់អំពីសុវត្ថិភាពទីកន្លែងធ្វើការ យើងនឹងវាយតម្លៃថាតើលក្ខខណ្ឌទីកន្លែងធ្វើការមានសុវត្ថិភាពដែរឬទេ។ ព័ត៌មានមកពីទាំងអ្នកទាមទារសុំ និងនិយោជក ក៏ដូចជាផ្នែកបទបញ្ញត្តិសុវត្ថិភាពថ្នាក់រដ្ឋ និងសហព័ន្ធត្រូវបានពិចារណា។

ការងារ មិនត្រូវបានចាត់ទុកថា ស័ក្តសមទេ ប្រសិនបើនិយោជកមិនមានឆន្ទៈ ឬមិនអាចផ្តល់ទីកន្លែងធ្វើការដ៏មានសុវត្ថិភាព តាមដែលតម្រូវទាមទារដោយច្បាប់ និងការណែនាំរបស់រដ្ឋ និងសហព័ន្ធ។ និយោជកមានការទទួលខុសត្រូវក្នុងការសបញ្ជាក់ថា ទីកន្លែងធ្វើការមានសុវត្ថិភាព និងអនុលោមតាមច្បាប់ និងការណែនាំអំពីសុវត្ថិភាពទីកន្លែងធ្វើការដ៏សមស្រប។

# ការទាមទារសុំដែលបោកបន្លំ

នរណាម្នាក់ដែលបានដាក់ពាក្យសុំទាមទារអត្ថប្រយោជន៍ប្រចាំសប្តាហ៍ត្រូវតែធ្វើការអះអាងដោយពិតប្រាកដថាតើពួកគេបានទទួលការផ្តល់ជូនឲ្យវិលទៅធ្វើការវិញដែរឬទេ។ នៅពេលអ្នកជូនដំណឹងពួកយើងថា អ្នកបានទទួលការផ្តល់ជូនឲ្យវិលត្រលប់ទៅធ្វើការវិញ យើងនឹងសួរអ្នក និងនិយោជកនូវសំណួរ ដើម្បីកំណត់ថាតើអ្នកនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍សម្រាប់ពេលអត់ការងារធ្វើដែរឬ

ទេ។ វាត្រូវបានចាត់ទុកថាជាការបោកបន្លំ ប្រសិនបើអ្នកផ្អិបទុកព័ត៌មានដោយចេតនា រួមទាំងថាតើអ្នកបដិសេធការផ្តល់ជូនការងារឬក៏អត់ផងដែរ។

## ផលវិបាកសម្រាប់ការអះអាងបោកបន្លំ

ការខកខានដោយចេតនាមិនបានរាយការណ៍ពីការងារ និងប្រាក់រកបានត្រឹមត្រូវ ភាពទំនេរសម្រាប់ធ្វើការ ឬមូលហេតុសម្រាប់ការផ្តាច់ឈប់ពីការងារអាចនាំឲ្យមានការបដិសេធអត្ថប្រយោន៍ ការបង់ទូទាត់សងអត្ថប្រយោជន៍វិញ ការដាកពិន័យផ្នែកហិរញ្ញវត្ថុ និងការកាត់ទោសបទល្មើសដែលអាចកើតមាន។

# ការដាក់បណ្តឹងឧទ្ធរណ៍

អ្នកមានសិទ្ធិប្តឹងឧទ្ធរណ៍ ប្រសិនបើអ្នកមិនយល់ស្របជាមួយការសម្រេចចិត្តដែលយើងបានធ្វើឡើងទាក់ទងនឹងអត្ថប្រយោជន៍សម្រាប់ពេលអត់ការងារធ្វើរបស់អ្នក។ ឧទាហរណ៍នៃការសម្រេចចិត្តដែលអ្នកអាចប្តឹងឧទ្ធរណ៍បានអាចនឹងរួមមានដូចជា៖

- ថាតើអ្នកមានមូលហេតុជាបុព្វហេតុល្អក្នុងការបដិសេធការផ្តល់ជូនការងារដែរឬទេ។
- ថាតើការផ្តល់ជូនការងារស័ក្តសមដែរឬទេ។

ស្វែងយល់បន្ថែម (ជាភាសាអង់គ្លេស) អំពីការប្តឹងឧទ្ធរណ៍អត្ថប្រយោជន៍ និងរបៀបក្នុងការដាក់បណ្តឹងឧទ្ធរណ៍